រាជបណ្ឌិត្យសភាកម្ពុជា

# ឥទ្ធិពលហ្វេសប៊ុកនៅក្នុងនយោបាយ និងសង្គមកម្ពុជា ឆ្នាំ២០០៨ - ២០២១

## ករណីសិក្សានៅរាជធានីភ្នំពេញ

## Facebook Influence in Cambodian Politics and Society

## 2008 – 2021

Case Study in Phnom Penh

ឆាយ សុផល

គ្រូណែនាំ ៖ បណ្ឌិត គិន ភា

និក្ខេបបទបណ្ឌិត

ជំនាញ ៖ វិទ្យាសាស្ត្រនយោបាយ

២០២៤

# មាតិកា

ឧទ្ទិសស្នាដៃ....................................................................................................i
សេចក្ដីថ្លែងអំណរគុណ.......................................................................................ii
អំណះអំណាង.....................................................................................................iv
មូលន័យសង្ខេបជាភាសាខ្មែរ..............................................................................v
មូលន័យសង្ខេបជាភាសាបរទេស........................................................................vii
អារម្ភកថា..........................................................................................................ix
សេចក្ដីផ្ដើម.........................................................................................................១
១- លំនាំបញ្ហា...................................................................................................១
២- ចំណោទបញ្ហានៃការស្រាវជ្រាវ........................................................................២
៣- គោលបំណងនៃការស្រាវជ្រាវ.........................................................................២
៤- ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ......................................................៣
៥- វិធីសាស្ត្រស្រាវជ្រាវ.........................................................................................៣
៦- សារប្រយោជន៍នៃការស្រាវជ្រាវ.......................................................................៤
៧- រចនាសម្ព័ន្ធនិក្ខេបបទ......................................................................................៥

## ជំពូកទី១
## ទម្លាប់និងគោលបំណងនៃការប្រើប្រាស់ហ្វេសប៊ុក ព្រមទាំងប្រព័ន្ធទូរគមនាគមន៍

ទម្លាប់និងគោលបំណងនៃការប្រើប្រាស់ហ្វេសប៊ុក ព្រមទាំងប្រព័ន្ធទូរគមនាគមន៍ ........................ ៨
១- ប្រជាសាស្ត្រ....................................................................................................៨
១.១- ភេទ ...........................................................................................................៨
១.២- អាយុ..........................................................................................................៨
១.៣- កម្រិតមុខរបរ...............................................................................................៩
១.៤- យេនឌ័រ.......................................................................................................៩
១.៥- កម្រិតសិក្សា.................................................................................................៩
២- ហ្វេសប៊ុកនៅកម្ពុជានៅឆ្នាំ២០០៨-២០២១ ..........................................................៩
៣- ប្រព័ន្ធទូរគមនាគមន៍ ....................................................................................... ១៥
៣.១- ស្ថានភាពទូទៅនៃការប្រើប្រព័ន្ធអ៊ីនធឺណិត.........................................................១៧

៣.២- សេវាគ្របដណ្តប់អ៊ីនធឺណិត ....................................................................................២០
៣.៣- ល្បឿនអ៊ីនធឺណិត.......................................................................................................២១
៣.៤- ស្ថិរភាពនៃការផ្គត់ផ្គង់អ៊ីនធឺណិត.................................................................................២២
៣.៥- តម្លៃអ៊ីនធឺណិត .......................................................................................................២៣
៤- ស្ថានភាពទូទៅនៃការប្រើប្រាស់ទូរសព្ទនៅកម្ពុជា .............................................................២៣
៤.១- សេវាគ្របដណ្តប់នៃប្រព័ន្ធទូរសព្ទ................................................................................២៥
៤.២- ល្បឿននៃប្រព័ន្ធទូរសព្ទ ..............................................................................................២៦
៤.៣- ស្ថិរភាពនៃការផ្គត់ផ្គង់នៃប្រព័ន្ធទូរសព្ទចល័ត ...............................................................២៧
៤.៤- តម្លៃប្រព័ន្ធសេវាទូរសព្ទចល័ត......................................................................................២៨
៥- ស្ថានភាពទូទៅនៃការប្រើប្រាស់ហ្វេសប៊ុក........................................................................៣១
៥.១- ពេលវេលានៃការចាប់ផ្តើមប្រើហ្វេសប៊ុក ........................................................................៣២
៥.២- ការប្រើប្រាស់បណ្តាញសង្គមលើសពីមួយ........................................................................៣៤
៥.៣- មធ្យោបាយប្រើប្រាស់ហ្វេសប៊ុករបស់អ្នកឆ្លើយតប.............................................................៣៦
៥.៤- ភាពញឹកញាប់នៃការប្រើអ្នកប្រើហ្វេសប៊ុករបស់អ្នកឆ្លើយតប...............................................៣៦
៥.៥- គោលបំណងរួមនៃការប្រើហ្វេសប៊ុករបស់អ្នកឆ្លើយតប ......................................................៣៧
៥.៦- ការចូលចិត្តតាមដាននយោបាយតាមហ្វេសប៊ុក ................................................................៣៩
៥.៧- ក្រុមអាយុ ភេទ និងមុខរបរ ដែលចាប់អារម្មណ៍នយោបាយតាមហ្វេសប៊ុក................ ៤១

## ជំពូកទី២
## ឥទ្ធិពលហ្វេសប៊ុកលើឥរិយាបថអ្នកនយោបាយនិងអ្នកបោះឆ្នោត

២- ឥទ្ធិពលហ្វេសប៊ុកលើឥរិយាបថអ្នកនយោបាយនិងអ្នកបោះឆ្នោត...................................៤៥
២.១- ចលនានយោបាយតាមហ្វេសប៊ុក...................................................................................៤៨
២.២- ហ្វេសប៊ុកជាស្ពានទំនាក់ទំនងរវាងអ្នកនយោបាយនិងអ្នកបោះឆ្នោត.......................................៦០
២.៣- ការទទួលសារនយោបាយតាមហ្វេសប៊ុក........................................................................៦៤
២.៤-ការទទួលសារនយោបាយតាមទម្រង់នៅក្នុងហ្វេសប៊ុក.........................................................៦៨
២.៥- ការបញ្ជូនសារនយោបាយតាមទម្រង់នៅក្នុងហ្វេសប៊ុក .......................................................៦៩
២.៦- ហ្វេសប៊ុកជាសង្វៀនប្រកួតរវាងអ្នកនយោបាយនិងអ្នកនយោបាយ.........................................៧០
២.៧- ឥទ្ធិពលហ្វេសប៊ុកលើការបោះឆ្នោត ...........................................................................៧៧
២.៧.១- ការប្រើប្រាស់ហ្វេសប៊ុកដើម្បីពិភាក្សានយោបាយ.........................................................៧៩
២.៧.២- ភាពញឹកញាប់នៃការពិភាក្សានយោបាយតាមហ្វេសប៊ុក ............................................ ៨០
២.៧.៣- ឥទ្ធិពលហ្វេសប៊ុកនិងការឃោសនាបោះឆ្នោត...........................................................៨១
២.៧.៤- ហ្វេសប៊ុកនិងការចេញទៅបោះឆ្នោត.........................................................................៨៧

# ជំពូកទី៣
# ហ្វេសប៊ុក ជះផលអវិជ្ជមាននិងវិជ្ជមានលើទិដ្ឋភាពនយោបាយនិងសង្គម


៣- ហ្វេសប៊ុក ជះផលអវិជ្ជមាននិងវិជ្ជមានលើទិដ្ឋភាពនយោបាយនិងសង្គម............................៩៣
៣.១- ហ្វេសប៊ុកនិងផលវិបាកដល់ពលរដ្ឋ........................................................................៩៦
៣.១.១- ផលវិបាកដោយសារអក្ខរកម្មព័ត៌មាននៅតាមហ្វេសប៊ុក...............................៩៦
៣.១.២- ការឆាប់ជឿព័ត៌មាននៅតាមហ្វេសប៊ុក.....................................................១០០
៣.១.៣- ការចែករំលែកព័ត៌មានតាមហ្វេសប៊ុក.....................................................១០២
៣.១.៤- ការបញ្ចេញមតិតាមហ្វេសប៊ុក..............................................................១០៥
៣.១.៥- អ្នកប្រើប្រាស់ហ្វេសប៊ុកនិងការបាត់បង់សីលធម៌.......................................១០៩
៣.១.៦- អ្នកប្រើប្រាស់ហ្វេសប៊ុកនិងការឆាប់មានកំហឹងចំពោះសារមិនល្អ..................១១២
៣.១.៧- ហ្វេសប៊ុកនិងសីលធម៌នយោបាយ..........................................................១១៦
៣.២- ហ្វេសប៊ុកនិងផលអវិជ្ជមានសម្រាប់អ្នកប្រើប្រាស់............................................១១៩
៣.២.១- ហ្វេសប៊ុកនិងការបាត់បង់កិត្តិយស..........................................................១២១
៣.២.២- ការជាប់ទោសទណ្ឌដោយសារការប្រើប្រាស់ហ្វេសប៊ុកមិនត្រឹមត្រូវ.................១២៥
៣.២.៣- ហ្វេសប៊ុកនាំឱ្យបាត់បង់ផលប្រយោជន៍...................................................១២៩
៣.២.៤- ហ្វេសប៊ុកធ្វើឱ្យអ្នកប្រើប្រាស់ចាញ់បោកទ្រព្យសម្បត្តិ...................................១៣១
៣.៣- ហ្វេសប៊ុកនិងផលវិបាកដល់អ្នកនយោបាយ......................................................១៣៤
៣.៣.១- ហ្វេសប៊ុកនិងការបាត់បង់តួនាទីរបស់មន្ត្រីនៅក្នុងស្ថាប័នរដ្ឋ..........................១៣៤
៣.៣.២- ហ្វេសប៊ុកនិងការបាត់បង់អំណាចបុគ្គល...................................................១៣៦
៣.៣.៣- ហ្វេសប៊ុកនិងការបាត់បង់អំណាចជាក្រុម.................................................១៣៩
៣.៣.៤- ហ្វេសប៊ុក នាំឱ្យមានការនិរទេសខ្លួននិងគ្មានសិទ្ធិធ្វើនយោបាយ.....................១៤១
៣.៤- ហ្វេសប៊ុកនិងផលវិបាកដល់សង្គម...............................................................១៤៣
៣.៤.១- ផលវិបាកក្នុងសង្គម.........................................................................១៤៣
៣.៤.២- ហ្វេសប៊ុកនិងប្រភេទនៃផលវិបាកមួយចំនួននៅក្នុងសង្គម............................១៤៥
៣.៥- ហ្វេសប៊ុកនិងច្បាប់.................................................................................១៦០
៣.៥.១- ឥទ្ធិពលហ្វេសប៊ុកនិងការរៀបចំច្បាប់.......................................................១៦០
៣.៥.២- ឥទ្ធិពលហ្វេសប៊ុកលើគំនិតផ្តួចផ្តើមការរៀបចំតាក់តែងច្បាប់........................១៦១
៣.៥.៣- ការបញ្ចេញទស្សនៈតាមហ្វេសប៊ុក ពាក់ព័ន្ធនឹងការរៀបចំតាក់តែងច្បាប់...........១៦២
៣.៥.៤- ឥទ្ធិពលហ្វេសប៊ុកនៅក្នុងដំណាក់កាលនៃការរៀបចំតាក់តែងច្បាប់...................១៦៥
៣.៥.៥- ឥទ្ធិពលហ្វេសប៊ុកលើការអនុវត្តច្បាប់.....................................................១៦៩
៣.៥.៦- ឥទ្ធិពលហ្វេសប៊ុកលើឥរិយាបថមន្ត្រីអនុវត្តច្បាប់.........................................១៧១
៣.៥.៧- ឥទ្ធិពលហ្វេសប៊ុកលើឥរិយាបថពលរដ្ឋចំពោះការគោរពច្បាប់........................១៧៣

៣.៥.៨- ហ្វេសប៊ុកនិងការរិតបន្តឹងការអនុវត្តច្បាប់....................................................១៧៤

៣.៥.៩- ហ្វេសប៊ុកនិងតុលាការ.......................................................................................១៧៩

៣.៥.១០- ហ្វេសប៊ុកនិងការធ្វើវិសោធនកម្មច្បាប់.......................................................១៨២

៣.៦- ហ្វេសប៊ុកនិងការផ្តល់សេវាសាធារណៈរបស់រដ្ឋ.......................................................១៨៣

៣.៦.១- ហ្វេសប៊ុកនិងឥរិយាបថក្នុងការផ្តល់សេវាសាធារណៈរបស់រដ្ឋ............................១៨៣

៣.៦.២- ការបញ្ចេញមតិតាមហ្វេសប៊ុក ពីសេវាសាធារណៈរបស់រដ្ឋ................................១៨៦

៣.៦.៣- ហ្វេសប៊ុកនិងការិយាធិបតេយ្យ...........................................................................១៨៩

៣.៦.៤- ហ្វេសប៊ុកនិងការទទួលខុសត្រូវលើការផ្តល់សេវាសាធារណៈរបស់រដ្ឋ..................១៩១

៣.៦.៥- ហ្វេសប៊ុកនិងការឆ្លើយតបពីថ្នាក់ដឹកនាំ........................................................១៩៣

៣.៦.៦- ហ្វេសប៊ុកនិងការធ្វើប្រតិភូកម្មអំណាចទៅថ្នាក់ក្រោមជាតិ...............................១៩៥

៣.៦.៧- ហ្វេសប៊ុកនិងការចំណាយពេលវេលា និងថវិការបស់ប្រជាពលរដ្ឋចំពោះការទទួលសេវាសាធារណៈរបស់រដ្ឋ.............................................................................................១៩៥

៣.៦.៨- ហ្វេសប៊ុកនិងគុណភាពនៃការផ្តល់សេវាសាធារណៈរបស់រដ្ឋ..............................១៩៧

៣.៦.៩- ហ្វេសប៊ុកនិងអំពើពុករលួយក្នុងការផ្តល់សេវាសាធារណៈរបស់រដ្ឋ....................១៩៨

៣.៦.១០- ហ្វេសប៊ុកនិងឥរិយាបថទំនាក់ទំនងរបស់មន្ត្រីផ្តល់សេវាសាធារណៈរបស់រដ្ឋ.....១៩៩

សេចក្តីសន្និដ្ឋាន.......................................................................................................២០២

អនុសាសន៍.................................................................................................................២០៨

គន្ថនិទ្ទេស.......................................................................................................................A

បញ្ជីរាយនាមអ្នកផ្តល់កិច្ចសម្ភាសន៍ស៊ីជម្រៅ..................................................................TT

ឧបសម្ព័ន្ធ......................................................................................................................UU

ក្រាហ្វិកនិងដ្យាក្រាម.......................................................................................................UU

ក្រាហ្វិក...........................................................................................................................UU

ដ្យាក្រាម..........................................................................................................................YY

បញ្ជីសំណួរ...................................................................................................................CCCC

# ឧទ្ទិសស្នាដៃ

ខ្ញុំបាទ **ឆាយ សុផល** សូមឧទ្ទិសស្នាដៃនេះជូនចំពោះ៖

- វិញ្ញាណក្ខន្ធលោកឪពុកនិងអ្នកម្ដាយរបស់ខ្ញុំ ដែលលោកបានតស៊ូចិញ្ចឹមបីបាច់ថែរក្សាខ្ញុំបាទនៅគ្រប់កាលៈទេសៈ ទោះប្រទេសជួបកលិយុគក៏ដោយ រហូតខ្ញុំបាទមានឱកាសបានបង្កើតស្នាដៃមួយនេះ។

- អ្នកប្រាជ្ញ បណ្ឌិត អ្នកស្រាវជ្រាវ និងបុព្វបុរសខ្មែរ និងបរទេសដែលបានបន្សល់ឯកសារខ្លះដែលជាតម្លៃសម្រាប់ការស្រាវជ្រាវរបស់ខ្ញុំ។

- វិញ្ញាណក្ខន្ធបុព្វបុរស បុព្វការីជនខ្មែរទាំងអស់ដែលបានបូជាជីវិតដើម្បីសន្តិភាព ការបង្រួបបង្រួមជាតិ និងដើម្បីសាសនានិងព្រះមហាក្សត្រ ជាពិសេសវិញ្ញាណក្ខន្ធជនរួមជាតិខ្មែររាប់លាននាក់ដែលបានបាត់បង់ជីវិតដោយអយុត្តិធម៌នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចន្លោះឆ្នាំ ១៩៧៧-១៩៧៩ ព្រមទាំងសម័យកាលបន្តបន្ទាប់ ដែលប្រទេសជួបសង្គ្រាមស៊ីវិល។

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទសូមគោរពថ្លែងអំណរគុណដោយស្មោះសអស់ពីដួងចិត្តចំពោះថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសស្ថាបនិកសន្តិភាព ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាអ្នកដឹកនាំ។ ដោយសារខ្ញុំបាទធ្លាប់បានឆ្លងកាត់ភ្លើងសង្គ្រាម របត់នយោបាយ និងមនោគមវិជ្ជាផ្សេងៗគ្នាអស់ជាងបីទសវត្សរ៍នៅក្នុងប្រទេសកម្ពុជា ដែលខ្មែរនិងខ្មែរបង្ហូរឈាមជាតិឯងជាពិសេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ ដែលជារបបឃោរឃៅយង់ឃ្នង ប្រល័យពូជសាសន៍ឯងអស់រាប់លាននាក់ ទើបខ្ញុំមិនអាចបំភ្លេចបាន និងដឹងច្បាស់ពីតម្លៃសន្តិភាពដែលមិនអាចកាត់ថ្លៃ។ ប្រសិនបើគ្មានសន្តិភាព ក៏គ្មានការអភិវឌ្ឍធនធានមនុស្ស ធនធានសង្គម ក៏ដូចជាធនធានប្រទេសទាំងមូល។ ជាពិសេសជាងនេះទៅទៀត បើគ្មានសន្តិភាព ខ្ញុំបាទក៏គ្មានឱកាសបានបន្តការសិក្សាថ្នាក់បណ្ឌិតដែរ។

ឆ្លៀតឱកាសនេះ ខ្ញុំបាទក៏សូមថ្លែងអំណរគុណចំពោះ ឯកឧត្តមបណ្ឌិត **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន ដែលលោកតែងតែលើកទឹកចិត្ត និងបង្កលក្ខណៈងាយស្រួលឱ្យខ្ញុំបាទជាមន្ត្រីក្រោមឱវាទបានបន្តការរៀនរហូតមក។

បន្ទាប់មក ខ្ញុំសូមអរគុណរាជបណ្ឌិត្យសភាកម្ពុជា ជាពិសេស ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ដែលតែងតែលើកទឹកចិត្តខ្ញុំបាទឱ្យបន្តរៀនយកថ្នាក់បណ្ឌិតដើម្បីជាប្រយោជន៍ដល់ខ្លួនឯងផង និងសង្គមជាតិផង ហើយឯកឧត្តមបណ្ឌិតសភាចារ្យក៏បានធ្វើជាសមាជិកវាយតម្លៃការពារនិក្ខេបបទចុងក្រោយរបស់ខ្ញុំបាទផងដែរ។

ខ្ញុំបាទមិនអាចបំភ្លេចបានឡើយចំពោះគុណបំណាច់របស់លោកគ្រូអ្នកគ្រូ រួមមាន ឯកឧត្តមបណ្ឌិត **គិន ភា** ឯកឧត្តមបណ្ឌិត **យង់ ពៅ** បណ្ឌិត **ព្រំ ទេវី** បណ្ឌិត **ប៉ាន់ ឧត្តរា** បណ្ឌិត **នេត បារ៉ុម** បណ្ឌិត **ភា ម៉ាធុល** និងសពបណ្ឌិត **ភិត លន់** ដែលលោកទាំងអស់បានបង្ហាត់បង្ហាញពុទ្ធិដល់ខ្ញុំបាទ ក៏ដូចជានិស្សិតរួមជំនាន់ទី៤ វគ្គ១ ដែលជាប្រទីបបង្ហាញផ្លូវឱ្យខ្ញុំបាទមានមូលដ្ឋានក្នុងការបង្កើតស្នាដៃនេះ។

ពិតជាមិនអាចប្រកែកបានទេដែលថា ឯកឧត្តមបណ្ឌិត **គិន ភា** គ្រូណែនាំ ឯកឧត្តមបណ្ឌិត **យង់ ពៅ** អគ្គលេខាធិការរាជបណ្ឌិត្យសភាកម្ពុជា និងជាប្រធានគណៈកម្មការកំណែលើកទី១ និងទី២ បណ្ឌិត **ជូ ច័ន្ទដារី** ប្រធានគណៈកម្មការតម្លៃការពារនិក្ខេបបទចុងក្រោយ ឯកឧត្តមបណ្ឌិត **ខៃក វីរៈ** បណ្ឌិត **ស៊ីន សំ** និងបណ្ឌិត **តូច សុទ្ធារី** ដែលលោកទាំងអស់បានផ្តល់យោបល់ប្រកបដោយពុទ្ធិ ពាក់ព័ន្ធនឹងការរៀបចំស្នាដៃនិក្ខេបបទនេះ។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណចំពោះ បណ្ឌិត **ហេង ហុកវេន** ព្រមទាំងមន្ត្រីនិងបុគ្គលិករដ្ឋបាល នៃមជ្ឈមណ្ឌលបណ្តុះបណ្តាលនៃរាជបណ្ឌិត្យសភាកម្ពុជា ដែលបានជួយផ្តល់មតិមួយចំនួន និងសម្រួលកិច្ចការខ្លះផ្នែកឯកសារសម្រាប់ស្នាដៃនេះដែរ។

ជាងនេះទៅទៀត ខ្ញុំបាទសូមនឹកគុណដល់វិញ្ញាណក្ខន្ធលោកឪពុកបង្កើត **ឃឹម គូ** ដែលលោកបានទទួលមរណភាពនៅពេលកងទ័ពខ្មែរក្រហមបានវាយចូលមកដល់ទីក្រុងភ្នំពេញនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងវិញ្ញាណក្ខន្ធអ្នកម្តាយ ង៉ែត គន្ធា ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ខ្ញុំបាទ

បានដឹងក្តី និងមានឱកាសដល់ពេលនេះ។

ព្រមពេលជាមួយគ្នានេះដែរ ខ្ញុំសូមអរគុណភរិយា **ឈុំ ដារ៉ា** ដែលតែងតែលើកទឹកចិត្ត និងផ្តល់ពេលវេលាឱ្យខ្ញុំបានបន្តរៀន និងស្រាវជ្រាវ បើទោះជានៅក្នុងគ្រួសារមានធុរៈច្រើនក៏ដោយ ខណៈកូនទាំងប្រាំរបស់ខ្ញុំបាទ និងចៅប្រុសបីផងបានជំរុញទឹកចិត្តខ្ញុំឱ្យប្រឹង ដើម្បីបញ្ជាក់ថា ការរៀនសូត្រគឺមិនចេះចប់ឡើយ ហើយពូជពង្សវង្សត្រកូលរបស់ពួកគេក៏ជាអ្នករៀនសូត្រដែរ។

ខ្ញុំបាទក៏សូមអរគុណមន្ត្រីរាជបណ្ឌិត្យសភាកម្ពុជា ជាពិសេសសាស្ត្រាចារ្យបណ្ឌិត ដែលបានជួយសម្រួលការងាររដ្ឋបាល និងនីតិវិធីមួយចំនួនក្នុងការរៀបចំនិក្ខេបបទសាកល្បងនេះ។

ទន្ទឹមនឹងនេះ ខ្ញុំបាទក៏មិនភ្លេចដែរចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ព្រមទាំងប្អូនៗនិស្សិត ដែលបានជួយសម្របសម្រួលទាំងនៅក្នុងបណ្ណាល័យ នៅការិយាល័យធ្វើការ ទាំងនៅក្នុងស្ថាប័ន និងនៅគេហដ្ឋាន ដើម្បីខ្ញុំបាទបានឯកសារ និងសម្ភាសទាំងជួបផ្ទាល់ និងតាមប្រព័ន្ធអនឡាញ (Online) ជាពិសេសតាម ហ្វេសប៊ុក(Facebook)។

ជាទីបញ្ចប់ខ្ញុំ សូមអរគុណបណ្ឌិត **មាឃ បូរ៉ា** និងលោក **ស៊ូ ផង់** ដែលបានជួយផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធក្នុងនិក្ខេបបទនេះ ដោយផ្អែកលើសំណេរនៅក្នុងវចនានុក្រមរបស់ស្នាព្រះហស្ត សម្តេចព្រះសង្ឃរាជគណៈមហានិកាយ **ជួន ណាត** ជោតញ្ញាណោ៕

# **អំណះអំណាង**

ខ្ញុំបាទ **ឆាយ សុផល** សូមអះអាងថា និក្ខេបបទស្តីពី «**ឥទ្ធិពលហ្វេសប៊ុកនៅក្នុងនយោបាយនិងសង្គមកម្ពុជា ឆ្នាំ២០០៨-២០២១ ករណីសិក្សានៅរាជធានីភ្នំពេញ**» ពិតជាស្នាដៃដែលខ្ញុំបានខិតខំប្រឹងប្រែងធ្វើដោយឈរលើមូលដ្ឋានវិទ្យាសាស្ត្រ ហើយផ្អែកលើប្រភពទាំងមនុស្ស និងឯកសារយ៉ាងច្បាស់លាស់ និងដ៏រឹងមាំ ក្នុងការអនុវត្តវិធីសាស្ត្រសរសេរនិក្ខេបបទថ្នាក់បណ្ឌិតនៅរាជបណ្ឌិត្យសភាកម្ពុជា។

រាជធានីភ្នំពេញ ថ្ងៃពុធ ទី១៥កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ត្រូវនឹងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤

**ហត្ថលេខា**

**ឆាយ សុផល**

**ពិនិត្យ និងឯកភាព**

រាជធានីភ្នំពេញ ថ្ងៃពុធ ទី១៥កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ត្រូវនឹងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤

**គ្រូណែនាំ**

**បណ្ឌិត គិន ភា**

# មូលន័យសង្ខេប

និក្ខេបបទស្តីពី «ឥទ្ធិពលហ្វេសប៊ុកនៅក្នុងនយោបាយនិងសង្គមកម្ពុជា ឆ្នាំ២០០៨-២០២១ ករណីសិក្សានៅរាជធានីភ្នំពេញ» ត្រូវបានរៀបចំឡើងក្នុងគោលបំណងវិភាគទៅលើឥទ្ធិពលហ្វេសប៊ុកនៅក្នុងនយោបាយនិងបញ្ហាសង្គមមួយចំនួន ព្រមទាំងផលវិជ្ជមាននិងអវិជ្ជមានខ្លះទៀតដែលកើតមានចំពោះបុគ្គល ក្រុម និងសង្គម នៅប្រទេសកម្ពុជាក្នុងចន្លោះឆ្នាំ២០០៨-២០២១។ ចាប់តាំងពីដើមឆ្នាំ២០០៨មក បណ្តាញផ្សព្វផ្សាយសង្គម (Social Media Network) ដូចជា ហ្វេសប៊ុក (Facebook) យូធូប (YouTube) ធ្វីតធ័រ (Twitter) ភ្លីកឃ័រ (Flicker) តេឡេក្រាម (Telegram) វ៉ាត់ស្អាប់ (WhatsApp) ឡាញ (Line) ម៉ាស្សិនជឺ (Messanger) និង តិកតុក (TikTok) ជាដើម បានចាប់ផ្តើមមានប្រជាប្រិយកាន់តែច្រើនឡើងគួរឱ្យកត់សម្គាល់ នៅក្នុងចំណោមប្រជាជនកម្ពុជា ក៏ដូចជាបណ្តាប្រទេសនៅក្នុងតំបន់និងសកលលោកដែរ។ នៅក្នុងចំណោមបណ្តាញផ្សព្វផ្សាយសង្គមទាំងនោះ ហ្វេសប៊ុក ត្រូវបានមហាជនសង្កេតឃើញថា ហាក់ដូចជាមានភាពលេចធ្លោជាងគេ ព្រោះថា បើទោះជាមនុស្សមួយចំនួនបានប្រើប្រាស់បណ្តាញផ្សព្វផ្សាយសង្គមផ្សេងៗក៏ដោយ ក៏ពួកគេបានភ្ជាប់តំណ (Link) ដាក់ចូលក្នុង ហ្វេសប៊ុក ដែរ។

ការសង្កេតជារួម ដោយសារតែ ហ្វេសប៊ុក មានប្រជាប្រិយ ងាយស្រួលប្រើដោយចំណាយប្រាក់តិចនិងបញ្ជូនសារស្ទើរគ្រប់ទម្រង់បានយ៉ាងលឿន ទើប ហ្វេសប៊ុក មានឥទ្ធិពលគួរឱ្យកត់សម្គាល់លើទិដ្ឋភាពនយោបាយនិងសង្គមកម្ពុជានាចន្លោះឆ្នាំ២០០៨-២០២១ ក៏ដូចជាឆ្នាំបន្តបន្ទាប់។ ប្រការនេះបាននាំឱ្យមានការផ្លាស់ប្តូរឥរិយាបថទាំងអ្នកនយោបាយ និងអ្នកគាំទ្រនយោបាយក្នុងការចូលរួមពិភាក្សានិងការបញ្ចេញមតិ ក៏ដូចជាការចូលរួមបោះឆ្នោត។ ទន្ទឹមនឹងនោះ ហ្វេសប៊ុក បានផ្លាស់ប្តូរឥរិយាបថមន្ត្រីផ្តល់សេវាសាធារណៈរបស់រដ្ឋ ដោយធ្វើឱ្យពួកគេមានចរិតរួសរាយ ការផ្តល់សេវាបានលឿន និងមានប្រសិទ្ធភាពជាងមុន ដោយបានកាត់បន្ថយការិយាធិបតេយ្យ និងអំពើពុករលួយជាដើម ហើយការផ្តល់សេវាកាន់តែមានតម្លាភាព និងគុណភាពជាងមុន។ បន្ថែមពីលើនេះ ហ្វេសប៊ុក មានឥទ្ធិពលលើការរៀបចំច្បាប់ ការធ្វើវិសោធនកម្មច្បាប់ ការអនុវត្ត និងការគោរពច្បាប់ទាំងក្នុងចំណោមអ្នកនយោបាយ និងមិននយោបាយ។ បន្ថែមពីលើនេះ ហ្វេសប៊ុក ក៏ត្រូវបានគេមើលឃើញថា បានជះឥទ្ធិពលអវិជ្ជមានផងដែរនៅក្នុងទិដ្ឋភាពនយោបាយនិងសង្គម។

ផ្អែកលើសម្មតិកម្មខាងលើ និក្ខេបបទស្តីពី «ឥទ្ធិពលហ្វេសប៊ុកនៅក្នុងនយោបាយនិងសង្គមកម្ពុជា ឆ្នាំ២០០៨-២០២១ ករណីសិក្សានៅរាជធានីភ្នំពេញ» បានព្យាយាមឆ្លើយសំណួរសំខាន់ៗចំនួនបីដូចខាងក្រោម៖

(១)- តើហ្វេសប៊ុកពិតជាមានឥទ្ធិពលលើការផ្លាស់ប្តូរឥរិយាបថអ្នកនយោបាយនិងអ្នកគាំទ្រនយោបាយ (មហាជន) ក្នុងការចូលរួម និងការពិភាក្សានយោបាយ ព្រមទាំងការឃោសនានិងការបោះឆ្នោត ដែរឬក៏យ៉ាងណា?

(២)- តើហ្វេសប៊ុកពិតជាមានឥទ្ធិពលលើការរៀបចំច្បាប់ ការធ្វើវិសោធនកម្មច្បាប់ ការអនុវត្ត និងការគោរពច្បាប់ដែរឬទេ ហើយវាមានឥទ្ធិពលលើការផ្លាស់ប្តូរឥរិយាបថនៃមន្ត្រីផ្តល់សេវាសាធារណៈរបស់រដ្ឋ យ៉ាងដូចម្តេច? និង

(៣)- តើហ្វេសប៊ុកមានផលអវិជ្ជមានអ្វីខ្លះដល់អ្នកនយោបាយ និងអ្នកមិនមែននយោបាយ រួមទាំងបញ្ហាសង្គមផ្សេងទៀតដោយរបៀបណា?

ក្នុងនិក្ខេបបទនេះ យើងខ្ញុំបានពឹងផ្អែកលើទិន្នន័យបែបបរិមាណវិស័យផងនិងគុណវិស័យផង ដែលធ្វើឡើងតែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ហើយចំពោះបរិមាណវិស័យ យើងខ្ញុំបានយកអ្នកឆ្លើយតបចំនួន៥០០នាក់ (ស្ត្រី៣០%) រួមមានអ្នកនយោបាយនិងមិននយោបាយ ព្រមទាំងអ្នកជំនាញវិទ្យាសាស្ត្រនយោបាយផង ដោយប្រមូលចម្លើយពីក្រុមអ្នកឆ្លើយតប តាមរយៈការជួបដោយផ្ទាល់ផងនិងធ្វើតាមប្រព័ន្ធអនឡាញ (Online)ផង។ សម្រាប់ការធ្វើតាមប្រព័ន្ធអនឡាញ (Online) នេះគឺតាមរយៈការបញ្ជូនបញ្ជីសំណួរក្នុងប្រព័ន្ធ 'Google Form' ហើយភ្ជាប់តំណទៅ ម៉ាស្សិនជី របស់ហ្វេសប៊ុក។

សម្រាប់គុណវិស័យវិញ យើងខ្ញុំបានផ្អែកលើឯកសារចំនួន៤៨ ក្នុងនោះមានសៀវភៅ របាយការណ៍ សុន្ទរកថា សេចក្តីថ្លែងការណ៍ សារដែលផ្សាយជាសាធារណៈ អត្ថបទព័ត៌មានរបស់ស្ថាប័នព័ត៌មាន ទាំងជាខេមរភាសានិងភាសាអង់គ្លេស ដែលទាក់ទិននឹងប្រធានបទ ដើម្បីបានទិន្នន័យ រួមជាមួយទិន្នន័យបែបបរិមាណវិស័យផង មកសំយោគគំនិត មុននឹងធ្វើសេចក្តីសន្និដ្ឋាននិងផ្តល់អនុសាសន៍នៅក្នុងនិក្ខេបបទនេះ។

## មូលន័យសង្ខេបជាភាសាបរទេស ( Abstract )

The thesis on "**Influence of Facebook in Cambodian Politics and Society (2008 – 2021) – Case Study in Phnom Penh**" is designed aiming to analyze the influence of Facebook in some political and social issues, as well as some other positive and negative effects to individuals, groups, and society in Cambodia between 2008 and 2021. Since the beginning of 2008, social media networks such as Facebook, YouTube, Twitter, Flicker, Telegram, WhatsApp, Line, Messenger and TikTok have started to gain significant popularity among Cambodians, as well as countries in the region and the globe. Among those social media networks, Facebook seems to be the most prominent because even though some people use other social media sites, they still link to in Facebook.

In general observation, Facebook has had significant influence on the Cambodian political landscape between 2008 and 2021 and beyond, leading to a change in attitudes of both politicians and political supporters for political debates and comments as well as participation in elections. At the same time, Facebook also seemed to change officials' attitudes toward public service delivery – making them has more friendly, providing service much faster and more effectiveness. In addition, Facebook seemed to have influence on law development and amendments, law implementation and obeying from both politicians and non-politicians, including negative impacts on the political landscape and society.

Based on the above hypothesis, this thesis project on **Influence of Facebook in Cambodian Politics and Society (2008 – 2021) – Case Study in Phnom Penh** will attempt to answer four key questions in which:

1. Does Facebook influence on the change in the attitude of politicians and political supporters (the public) for participation in political debate, campaign and voting?
2. Does Facebook influence on the state's legal drafting, law amendments, law implementation and respects; and influence on behavior change of the state-service providers? And,
3. How does Facebook have any negative effect on politicians and non-politicians, as well as other social issues?

In this study, we relied on both quantitative and qualitative data, conducted only in Phnom Penh, and for quantitative data we targeted 500 respondents (30% women)

in which there are politicians and non- politicians, including political experts and scientists, through both online and face-to-face meetings. For online work, we sent questionnaires through ‘Google Form’ system and linked to messenger of Facebook.

For the quantitative data, we based on 488 documents – books, reports, speeches, statements, public messages and news articles of media organizations in both Khmer and English languages so that we could have the data and included with the qualitative ones in order to make conclusion before giving recommendation in the thesis.

# អារម្ភកថា

ជាទូទៅ យើងខ្ញុំសង្កេតឃើញថា បណ្តាញផ្សព្វផ្សាយសង្គម (Social Media Network) ដូចជា ហ្វេសប៊ុក (Facebook) យូធ្យូប (YouTube) ធ្វីតធ័រ (Twitter) ភ្លីកឃ័រ (Flicker) អ៊ីនស្តាក្រាម (Instagram) តេឡេក្រាម (Telegram) វ៉ាត់អាប់ (WhatsApp) ឡាញ (Line) ម៉ាស្សិនជឺ (Messanger) និង តិកតុក (TikTok) ជាដើម បានចាប់ផ្តើមមានប្រជាប្រិយកាន់តែច្រើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងចំណោមប្រជាជនកម្ពុជាចាប់ពីឆ្នាំ២០០៨មក។

នៅចន្លោះឆ្នាំ២០០៨ និងឆ្នាំ២០២១ ក្នុងគ្រាដែលបណ្តាញផ្សព្វផ្សាយសង្គម ជាពិសេស ហ្វេសប៊ុក កាន់តែមានឥទ្ធិពលនៅក្នុងនយោបាយកម្ពុជា មេដឹកនាំនយោបាយ អ្នកនយោបាយ និងមិននយោបាយ រួមទាំងអ្នកចលនាសង្គមផង បានឆក់ឱកាសទាញយកប្រយោជន៍ពីបណ្តាញទាំងនេះ ជាពិសេស ហ្វេសប៊ុក។

នៅក្នុងចំណោមបណ្តាញផ្សព្វផ្សាយសង្គមផ្សេងៗ ហ្វេសប៊ុក ត្រូវបានអ្នកប្រើប្រាស់មើលឃើញថា មានលក្ខណៈទូលំទូលាយជាង ព្រោះវាជាបណ្តុំនៃបណ្តាញផ្សព្វផ្សាយសង្គមដទៃទៀត ដែលបានភ្ជាប់តំណ (Link) បាន ពោលគឺ ហ្វេសប៊ុក ជាទីលានផ្ទុកសារចម្រុះ ទាំងសំណេរ សំឡេង និងរូបភាព (រូបថត និង វីដេអូ)។ សូម្បីតែគេហទំព័រ (Website) និងប្លុក (Blog) ដែលមានជាយូរមកហើយ ក៏ត្រូវបានអ្នកប្រើប្រាស់ភ្ជាប់តំណចូលមក ហ្វេសប៊ុក ដែរ។ ម្យ៉ាងវិញទៀត តេឡេក្រាម វ៉ាត់ស្អាប់ និងទីកតុក ជាដើម ក៏ត្រូវបានអ្នកប្រើប្រាស់យកដំណឹងផ្សេងៗមានទាំងសំណេរ រូបភាព និងរូបវីដេអូ មកភ្ជាប់តំណក្នុង ហ្វេសប៊ុក ដែរ ហើយបានចែករំលែកពីម្នាក់ទៅម្នាក់ និងពីក្រុមមួយទៅក្រុមមួយ។

ដោយសារតែវត្តមាននៃ ហ្វេសប៊ុក នេះហើយ ទើបធ្វើឱ្យមានការផ្លាស់ប្តូរឥរិយាបថមេដឹកនាំនយោបាយក្នុងការបញ្ជូនសារ និងរបៀបវារៈនយោបាយរបស់ខ្លួនទៅកាន់មហាជន ខណៈអ្នកគាំទ្រនយោបាយក៏បានផ្លាស់ប្តូរឥរិយាបថផងដែរ ដោយយក ហ្វេសប៊ុក ជាមធ្យោបាយទទួលសារនិងចែករំលែកសារផ្សេងៗបន្ត។ ទន្ទឹមនឹងនោះ មហាជន ឬថា អ្នកគាំទ្រនយោបាយ បានយក ហ្វេសប៊ុក ជាមធ្យោបាយចូលរួមនិងពិភាក្សានយោបាយ ហើយចូលរួមឃោសនាបោះឆ្នោត និងចេញទៅបោះឆ្នោតដើម្បីជ្រើសរើសតំណាងដែលខ្លួនពេញចិត្ត ឱ្យដឹកនាំមូលដ្ឋាននិងប្រទេសជាតិ។ បន្ថែមពីលើនេះ ហ្វេសប៊ុក ក៏ត្រូវបានគេមើលឃើញថា បានជំរុញឱ្យការផ្តល់សេវាសាធារណៈរបស់រដ្ឋកាន់តែមានតម្លាភាព និងគុណភាពកាន់តែល្អជាងមុន ហើយឥរិយាបថរបស់អ្នកផ្តល់សេវាកាន់តែទន់ភ្លន់និងរួសរាយ។

ម្យ៉ាងវិញទៀត ដោយសារតែឥទ្ធិពលហ្វេសប៊ុក ទើបធ្វើឱ្យមេដឹកនាំនយោបាយកម្ពុជារៀបចំតាក់តែងច្បាប់ថ្មីៗមួយនិងធ្វើសោធនកម្មច្បាប់ រួមទាំងការបង្កើនការអនុវត្តនិងការគោរពច្បាប់ផងដែរ។

យ៉ាងណាក៏ដោយ ទន្ទឹមនឹងមានផលវិជ្ជមានដល់អ្នកនយោបាយនិងមិននយោបាយ ក៏ដូចជាសង្គម ហ្វេសប៊ុក ក៏ត្រូវបានគេមើលឃើញថា បានជះឥទ្ធិពលអវិជ្ជមានខ្លះផងដែរ ដែលពេលខ្លះនាំឱ្យខាតប្រយោជន៍ទាំងផ្នែកនយោបាយនិងសេដ្ឋកិច្ច បាត់បង់អំណាច តួនាទី សេចក្តីថ្លៃថ្នូរ អសោចកេរ្តិ៍ ហើយក៏មានអ្នកខ្លះបានជាប់ទោសទណ្ឌតាមផ្លូវតុលាការនិងបាននិរទេសខ្លួន។

កន្លងមក យើងខ្ញុំបានសង្កេតឃើញថា មេដឹកនាំនយោបាយ សកម្មជននយោបាយ និងអ្នកទទួលផលនយោបាយ រួមទាំងអ្នកជំនាញនិងអ្នកសិក្សាវិទ្យាសាស្ត្រនយោបាយផង បានប្រើប្រាស់ ហ្វេសប៊ុក ធ្វើជាមធ្យោបាយទំនាក់ទំនង ការចែករំលែក និងទទួលដំណឹងផ្សេងៗពីបញ្ហានយោបាយ និងសង្គមទូទៅដែរ នៅជុំវិញពិភពលោក។ ក្រៅពីអាចកែប្រែឥរិយាបថសង្គមបាន យើងខ្ញុំក៏បានសង្កេតឃើញដែរថា ហ្វេសប៊ុក តែងតែត្រូវបានអ្នកនយោបាយយកចិត្តទុកដាក់បំផុតក្នុងការបញ្ជូនសារ និងរបៀបវារៈនយោបាយរបស់ខ្លួនទៅកាន់មហាជន។ មិនតែប៉ុណ្ណោះ ទាំងគណបក្សនយោបាយនិងអ្នកនយោបាយបានយក ហ្វេសប៊ុក ជាទីលានវាស់ស្ទង់មតិមហាជន ជាកន្លែងធ្វើតេស្តឬសាកល្បង និងជាឧបករណ៍នយោបាយ ដើម្បីកៀរគរអ្នកគាំទ្រតាមរយៈវិធីផ្សេងៗ ដូចជាការដាក់ចេញពាក្យស្លោក និងចេញសារជាសំណេរ ជារូបភាព និងជាវីដេអូជាដើម។ ជាងនេះទៅទៀត គណបក្សនយោបាយនិងអ្នកនយោបាយក៏បានយក ហ្វេសប៊ុក ធ្វើជាឧបករណ៍នយោបាយ ដើម្បីកេងចំណេញនិងបំបាក់ដៃគូជាដើម ហើយជាទីលានធ្វើប្រជាភិថុតិ ដើម្បីបញ្ចើចបញ្ចើរ បញ្ឆោតគ្នា និងលាបពណ៌គ្នា ដែលនាំឱ្យអ្នកនយោបាយនិងបក្សនយោបាយទទួលរងគ្រោះផងដែរ។

ដើម្បីជាឯកសារជំនួយស្មារតី ការស្រាវជ្រាវស្តីពី «ឥទ្ធិពលហ្វេសប៊ុកនៅក្នុងនយោបាយនិងសង្គមកម្ពុជា ឆ្នាំ២០០៨ - ២០២១ ករណីសិក្សានៅរាជធានីភ្នំពេញ» នេះត្រូវតែបង្ហាញចាំបាច់ពីឥទ្ធិពលរបស់ហ្វេសប៊ុក ដែលជាផ្នែកមួយនៃបណ្តាញផ្សព្វផ្សាយសង្គម នៅក្នុងនយោបាយនិងសង្គមកម្ពុជា ដើម្បីជាប្រយោជន៍សម្រាប់អ្នកនយោបាយនិងមិននយោបាយ រួមទាំងអ្នកសិក្សាចាស់ថ្មីពាក់ព័ន្ធនឹងប្រធានបទនេះ គិតគូរពិចារណាប្រកបដោយហេតុនិងផល ហើយដើម្បីយកទៅប្រើប្រាស់តាមជំនាញរៀងៗខ្លួននៅក្នុងសកម្មភាពនយោបាយនិងទំនាក់ទំនងសង្គម។

ហេតុដូច្នេះ យើងខ្ញុំសង្ឃឹមថា និក្ខេបបទស្តីពី «ឥទ្ធិពលហ្វេសប៊ុកនៅក្នុងនយោបាយនិងសង្គមកម្ពុជា ឆ្នាំ២០០៨-២០២១ ករណីសិក្សានៅរាជធានីភ្នំពេញ» អាចជាឯកសារវិទ្យាសាស្ត្រជំនួយស្មារតីសម្រាប់អ្នកប្រើប្រាស់បណ្តាញសង្គមផ្សេងៗ ជាពិសេស ហ្វេសប៊ុក ទាំងអ្នកនយោបាយនិងមិននយោបាយ ដើម្បីទាញយកប្រយោជន៍និងប្រាសចាកពីបញ្ហានានា។